**The Royal Women's Hospital Information for Women**

**4. Depo Provera - ការចាក់ថ្នាំបង្ការកុំឲ្យមានផ្ទៃពោះ**

*ខែមេសា ឆ្នាំ 2004*

## 4. DEPO PROVERA - A CONTRACEPTIVE INJECTION

## ហេតុអ្វីបានជាប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ?

**ការបង្ការមិនឲ្យមានផ្ទៃពោះ គឺជាការចាំបាច់ បើអ្នកចង់ចៀសវាងផ្ទៃពោះដែលមិនចង់បាន និង ជំងឺកាមរោគ។**
រៀងរាល់ខែ អូវែររបស់ស្ត្រីផលិតពងមេជីវិត។ នៅពេលដែលបុរសបញ្ចេញទឹកកាម ទឹកកាមនេះមានមេជីវិតបុរសរាប់ លាន។ វាត្រូវការតែមេជីវិតបុរសនេះមួយប៉ុណ្ណោះ ដើម្បីចូលទៅបង្កាត់ក្នុងពងមេជីវិតស្ត្រី ហើយចាប់ផ្តើមមានផ្ទៃពោះ។ បើគូស្រករធ្វើការរួមរ័កនឹងគ្នា (លិង្គនៅក្នុងរន្ធយោនី) ហើយគ្មានការប្រុងប្រយ័ត្នជាមុនទេនោះ ស្ត្រីមានលទ្ធភាពខ្ពស់ក្នុងការមានផ្ទៃពោះ។ ការប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ អនុញ្ញាតឲ្យអ្នករួមរ័ក ហើយចៀសវាងការមានផ្ទៃពោះដោយ អចេតនា។

## ស្រោមអនាម័យ មិនមែនជាគំនិតល្អជានិច្ចទ្បើយ

ប្រទេសអូស្ត្រាលី មានជំងឺកាមរោគថ្មីជាង 20 000 ក្នុងមួយឆ្នាំៗ។ ជំងឺកាមរោគទូទៅបំផុតគឺ chlamydia ដែលអាចធ្វើឲ្យមិនអាចមានកូនបាន បើទុកចោលមិនព្យាបាលទេនោះ។ ស្រោមអនាម័យគឺជាការការពារប្រសើរបំផុតរបស់អ្នកទល់នឹងជំងឺកាមរោគ។ បើអ្នកប្រើស្រោមអនាម័យនិងប្រេងធ្វើពីជាតិទឹក នៅរាល់ពេលដែលអ្នករួមភេទ អ្នកនឹងមានឱកាសតិចក្នុងការឆ្លង HIV/AIDS និងជំងឺកាមរោគ (STIs)។

## Depo Provera

Depo Provera គឺជាអ័រម៉ូនដែលប្រើសំរាប់ជាវិធីបង្ការកុំឲ្យមានផ្ទៃពោះ។ អ័រម៉ូននេះត្រូវបានផ្តល់ឲ្យតាមរយៈការចាក់ នឹងម្ជុល ហើយឥទ្ធិពលរបស់វានឹងមានរយៈពេលបីខែ នៅគ្រាចាក់ម្តងៗ។ អ័រម៉ូននេះ មានលក្ខណៈស្រដៀងគ្នានឹង progesterone ដែរ ដែលជាអ័រម៉ូនចំបងពីរបង្កើតដោយអូវែររបស់ស្ត្រី ក្នុងអម្លុងដំណើរវិលចុះឡើងធម្មតារបស់ស្ត្រី។

**របៀបបំពេញមុខងាររបស់វា**
នៅពេលដែលស្ត្រីមាន Depo Provera រាងកាយនាងដឹងអំពីវត្តមាននៃអ័រម៉ូន ដើម្បី"បិទ"ការបង្កើតអ័រម៉ូនរបស់នាង ផ្ទាល់។ ដោយហេតុនេះ អូវែររបស់នាងនឹងមិនបញ្ចេញពងមេជីវិតស្ត្រីទេ ហើយនេះជារបៀបបង្ការមិនឲ្យមានមានផ្ទៃ ពោះ។ របៀបនេះមានលក្ខណៈស្រដៀងគ្នាជាខ្លាំងទៅនឹងរបៀបដែល "The Pill" (ថ្នាំគ្រាប់)បំពេញមុខងារ។ ជួនកាលទៅ Depo Provera ក៏ត្រូវបានប្រើសំរាប់ព្យាបាល endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង)ផងដែរ។

**ប្រសិទ្ធភាពរបស់វា**
Depo Provera គឺជាវិធីបង្ការកុំឲ្យមានផ្ទៃពោះមានប្រសិទ្ធភាពខ្លាំង ខ្លាំងជាងថ្នាំគ្រាប់គួបផ្សំទៅទៀត។ បើស្ត្រី 100 នាក់ប្រើ Depo Provera អស់ពេល 1 ឆ្នាំ ស្ត្រីប្រហែលម្នាក់តែប៉ុណ្ណោះដែលនឹងមានផ្ទៃពោះ ពោលគឺ ចំនួន 99 នាក់ទៀត

នឹងគ្មានផ្ទៃពោះទេ។ គ្មានទំរង់ណាមួយនៃវិធីបង្ការកុំឲ្យមានផ្ទៃពោះ មានប្រសិទ្ធភាពទាំងស្រុងឡើយ។ Depo Provera នឹងមានប្រសិទ្ធភាពតទៅទៀត នៅពេលចាក់ថ្នាំនេះរៀងរាល់ពេលបីខែម្តង តាមពេលកំណត់តែប៉ុណ្ណោះ។

### ផលវិបាក

### រដូវ

ដោយសារតែអ័រម៉ូនមានកំរិតទាប ស្ត្រីភាគច្រើនមានស្រទាប់ក្នុងនៃស្បូនតិចតួចណាស់ ហើយមានរដូវកាន់តែចុះថយ។ ក្រោយពីចាក់ថ្នាំនេះបានពីរបីលើកមក ស្ត្រីជាច្រើននឹងគ្មានរដូវទាល់តែសោះ ដោយសារតែពុំមានការបង្កើតស្រទាប់ក្នុងនៃស្បូនសំរាប់ជំរុះចោលឡើយ។ ស្ត្រីខ្លះនឹងមានឈាមធ្លាក់ដែលធ្វើឲ្យរំខាន ហើយជាធម្មតា គឺតិចតួចនិងមិនប្រក្រតី។ នៅពេលម្តងម្កាល ស្ត្រីនឹងមានឈាមធ្លាក់ច្រើនធ្វើឲ្យលំបាក ដែលជាធម្មតាអាចគ្រប់គ្រងបានដោយសារការព្យាបាលប្រើអ័រម៉ូន។

### ផលវិបាកផ្សេងទៀត

- ពេលខ្លះ មានការឡើងទម្ងន់បន្តិច យ៉ាងណាមិញស្ត្រីជាច្រើនពុំមានការផ្លាស់ប្តូរទេ ហើយខ្លះទៀតស្រកទម្ងន់
- ស្ត្រីខ្លះអាចឈឺក្បាល ឆ្អល់ពោះ ហើប្តូរអារម្មណ៍យ៉ាងរហ័ស
- ចំណង់ក្នុងការរួមភេទរបស់ស្ត្រីខ្លះបានចុះថយ ជាពិសេសចំពោះស្ត្រីដែលរហ័សកើតមានការលំបាកចិត្ត
- ស្ត្រីមួយចំនួនតូច ជួបប្រទះនឹងផលវិបាកផ្សេងទៀត ដែលអាចបង្កក្តីរំខាន ប៉ុន្តែមិនទំនងជាមានភាពធ្ងន់ធ្ងរទេ។ ផលវិបាកទាំងនេះមានរួមទាំងប្រតិកម្មទំនាស់ ការទុកវត្ថុរាវក្នុងខ្លួន និង ឈឺដោះ។

## គុណសម្បត្តិ និង គុណវិបត្តិនៃ Depo Provera?

### គុណសម្បត្តិ

- Depo Provera មានប្រសិទ្ធភាពខ្លាំង ព្រមជាមួយនឹងបរាជ័យតាមកំរិតទាបជាខ្លាំង។
- ចំពោះស្ត្រីជាច្រើន ការបាត់បង់រដូវគឺជាគុណសម្បត្តិមួយដោយមានភាពធូរស្រាលនៃរោគសញ្ញាទាំងឡាយ ដូចជាភាពតានតឹងនៅមុនពេលមានរដូវ និង ការឈឺចាប់ពេលមានរដូវ។
- Depo Provera ក៏ទំនងជាធ្វើឲ្យមានការកាត់បន្ថយលទ្ធភាពគ្រោះថ្នាក់នៃការកើតមានរោគមហារីកអូវែរ មហារីកស្បូន endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង)និង លទ្ធភាពនៃដំបៅក្នុង ម៉្តុសាច់ដុំឆ្អឹងត្រគាក។
- ការចាក់ថ្នាំនេះ ត្រូវបានធ្វើទៅនៅពេល 12 អាទិត្យម្តង ហើយមិនតម្រូវឲ្យមានកិច្ចខិតខំផ្សេងទៀត ឬ ការចងចាំឡើយ។

### គុណវិបត្តិ

- ស្ត្រីខ្លះពុំចង់ទៅជួបវេជ្ជបណ្ឌិតរបស់ខ្លួននៅរៀងរាល់ពេលបីខែម្តង ដើម្បីចាក់ថ្នាំឡើយ។
- ស្ត្រីខ្លះជួបប្រទះនឹងផលវិបាកនានាដូចដែលបានពណ៌នារួចមកហើយ ដែលអាចបង្កភាពលំបាកឬភាពសៅហ្មង
- នៅពេលចាក់ថ្នាំហើយ គេមិនអាចដកយកអ័រម៉ូននេះចេញបានទេ។ បើស្ត្រីម្នាក់ចង់បញ្ឈប់ Depo Provera នោះនាងត្រូវតែរង់ចាំរហូតដល់វាសាបរលាបអស់។ ចំពោះស្ត្រីខ្លះ ការមានរដូវអាចយឺតយ៉ាវក្នុង ការវិលមកវិញក្រោយពីបានបញ្ឈប់ការចាក់ថ្នាំហើយ; ជួនកាលទៅ ស្ត្រីអាចត្រូវការពេលដល់ទៅ 6 ខែឬ 12 ខែ។ យ៉ាងណាមិញចំនួនជាងពាក់កណ្តាលនឹងមានផ្ទៃពោះក្នុងរង្វង់ពេល 12 ខែ ហើយជាង 90 ភាគរយ ក្នុងរង្វង់ពេលពីរឆ្នាំ។

### កិច្ចការផ្សេងទៀតដែលត្រូវគិត

អ័រម៉ូនមានកំរិតទាប នៅក្នុងពេលប្រើ Depo Provera ដូច្នេះគេមានការបារម្ភខ្លះថា ហេតុការណ៍នេះអាចបណ្តាលឲ្យឆ្អឹងខ្លះទៅជាស្តើង (osteoporosis) ចំពោះស្ត្រីដែលប្រើ Depo Provera អស់រយៈពេលយូរ។ គេមិនទាន់ដឹងសេចក្តី

សំខាន់នៃការអះអាងនេះនៅឡើយទេ  ប៉ុន្តែមានការរំពឹងថា ការផ្លាស់ប្តូរនឹងកើតមានឃើតជាងពេលកើតមានធម្មតានៅក្រោយពីលែងមានរដូវតទៅទៀត  ហើយប្រែក្រឡាស់មកវិញ ក្រោយពីបញ្ឈប់ការចាក់ថ្នាំនេះ។

ជាទូទៅ ស្ត្រីបារម្ភអំពីថ្នាំគ្រប់ប្រភេទទាំងអស់ និង រោគមហារីក។ ទោះជាវាមានការលំបាកខ្លាំងណាស់ដើម្បីបង្ហាញនូវការគ្មានលទ្ធភាពគ្រោះថ្នាក់ទាំងស្រុងក្តី  ក៏គ្មានការបង្ហាញថា Depo Provera មានឥទ្ធិពលណាមួយទៅលើលទ្ធភាពគ្រោះថ្នាក់នៃការកើតមានរោគមហារីកដោះឡើយ។ គេគួរកត់សំគាល់ថា ថ្នាំនេះទំនងជាខ្លាំងក្នុងការមានឥទ្ធិពលការពារទល់នឹងរោគមហារីកអូវែរនិងស្រទាប់ក្នុងរបស់ស្បូន។ គ្មានការបង្ហាញអំពីការកើតមានឥទ្ធិពលមិនល្អទៅលើភាពធំលូតលាស់របស់ទារកទេ  បើចាក់ Depo Provera នៅពេលដែលស្ត្រីមានផ្ទៃពោះរួចទៅហើយនោះ ឬ នៅក្នុងករណី ដ៏កំរនោះស្ត្រីអាចមានផ្ទៃពោះ ទោះជាមានការចាក់ថ្នាំនេះក៏ដោយ។

## អ្នកណាទៅដែលអាចប្រើ Depo Provera?

Depo Provera អាចប្រើដោយស្ត្រីភាគច្រើន ដែលគ្មានបញ្ហារោគធ្ងន់ធ្ងរណាមួយ និងដោយស្ត្រីជាច្រើនដែលប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ តាមទំរង់ផ្សេងទៀត។ ថ្នាំនេះក៏អាចសក្តិសមផងដែរចំពោះស្ត្រីដែលមិនអាចលេបថ្នាំគ្រាប់គួបផ្សំដោយសារតែមូលហេតុរោគ។

## អ្នកណាទៅដែលមិនគួរប្រើ Depo Provera?

Depo Provera មិនសក្តិសមចំពោស្ត្រីដែលកំពុងជួបប្រទះនឹងស្ថានភាពដូចតទៅនេះ :

- ជំងឺធ្លាក់ឈាម ឬ ប្រើថ្នាំប្រឆាំងការកកឈាម
- ការធ្លាក់ឈាមមិនធម្មតា ដែលគ្មានរោគវិនិច្ឆ័យ
- ប្រវត្តិនៃរោគមហារីកតាមទំរង់ខ្លះ
- បញ្ហាជំងឺធ្ងន់ធ្ងរជាក់លាកផ្សេងទៀត
- មានផ្ទៃពោះរួចទៅហើយ
- ចង់មានផ្ទៃពោះ ក្នុងរង្វង់ពេល 12 ខែ។

## ទីកន្លែងទទួលពត៌មានបន្ថែម

**Women's Health Information Centre (RWH)**
(03) 9344 2007
1800 442 007 (ទូរស័ព្ទឥតគិតថ្លៃ) អ៊ីមែល : whic@rwh.org.au
http://wellwomens.rwh.org.au

# ប័ណ្ណពត៌មានឯទៀតរបស់ RWH ដែលអាចមានប្រយោជន៍សំរាប់អ្នក

RWH មានប័ណ្ណពត៌មានផ្សេងៗជាភាសាច្រើន នៅតាមអ៊ីនធើរណិត។ បើអ្នកចង់បានពត៌មានបន្ថែម អ្នកអាចបើកមើលវិបសៃផ្សព្វផ្សាយសុខភាពរបស់យើង។ អាសយដ្ឋានគឺ http://wellwomens.rwh.org.au

អ្នកក៏អាចសុំឲ្យអ្នកថែទាំអ្នកនៅ Royal Women's Hospital ផ្តល់ប័ណ្ណពត៌មានឯទៀតអំពី វិធីបង្ការកុំឲ្យមានផ្ទៃពោះផងដែរ។ សុំយក :

ទី 1 *វិធីបង្ការកុំឲ្យមានផ្ទៃពោះ ជំរើសរបស់អ្នក*
ទី 2 *ស្រោមអនាម័យ និង ស្រោម Diaphragms*
ទី 3 *The Pill (ថ្នាំគ្រាប់)*
ទី 5 *Implanon – ការវះផ្សាំបង្ការកុំឲ្យមានផ្ទៃពោះ*
ទី 6 *IUD (Intra Uterine Device)[ឧបករណ៏ដាក់ក្នុងស្បូន]*